# ប្រវត្តិនិងវិវត្តន៍របស់ស្ថាប័នព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០២៤

*ដោយៈ បណ្ឌិត* ***ហែម ឡាច***
*ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

*ក្រោយការបោះឆ្នោតជាសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ វិបត្តិនយោបាយផ្ទៃក្នុងមួយបានកើតឡើង។ ដើម្បីដោះស្រាយវិបត្តិនេះ កិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សនយោបាយទាំងពីរ គឺគណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិចបានប្រារព្ធឡើងនៅថ្ងៃទី១២និង១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ នាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ដែលនៅពេលនោះព្រះអង្គទ្រង់ជាព្រះមហាក្សត្រនៃព្រះរាជាណា-ចក្រកម្ពុជា ។*

*តាមរយៈលទ្ធផលនៃកិច្ចប្រជុំកំពូលនេះ ស្ថាប័នព្រឹទ្ធសភា ត្រូវបានបង្កើតឡើង និងក្លាយជាចំណែកមួយនៃស្ថាប័ននីតិប្បញ្ញត្តិជាតិ ដែលមានពីរថ្នាក់ បន្ទាប់ពីរដ្ឋធម្មនុញ្ញនីតិកាលទី២ បានធ្វើវិសោធន-កម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយការតែងតាំងនិងមានអាណត្តិ៥ឆ្នាំ។ សមាជិកចំនួន៦១រូបត្រូវបានជ្រើសរើសពីក្នុងចំណោមឥស្សរជនជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២។ ព្រឹទ្ធសភា**នីតិកាលទី១** បានបើកសម័យប្រជុំលើកទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។*

*ព្រឹទ្ធសភា**នីតិកាលទី២** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យទី២២ ខែមករា ឆ្នាំ២០០៦ ដោយមានអាណត្តិ៦ឆ្នាំ។ ព្រឹទ្ធសភា នីតិកាលទី២ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។*

*ព្រឹទ្ធសភា**នីតិកាលទី៣** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។ ព្រឹទ្ធសភា នីតិកាលទី៣ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ក្រោមព្រះរាជាធិបតីភាពដ៏*

ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ព្រឹទ្ធសភា**នីតិកាលទី៤** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈឆ្នាំ២០១៨។ ព្រឹទ្ធសភា នីតិកាលទី៤ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ព្រឹទ្ធសភា**នីតិកាលទី៥** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃទី២៥ ខែកុម្ភៈឆ្នាំ២០២៤។ ព្រឹទ្ធសភា នីតិកាលទី៥ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងចំណោមសមាជិកព្រឹទ្ធសភា៦២រូបបច្ចុប្បន្ននេះ មាន៥៨រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកល២ រូប ជ្រើសតាំងដោយរដ្ឋសភា និង២ រូបតែងតាំងដោយព្រះមហាក្សត្រ ។

## ១-ការរៀបចំព្រឹទ្ធសភា

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន។ ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[1] សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។ សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសរើសសាជាថ្មីបាន។ នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់៦ឆ្នាំ។ ប៉ុន្តែនីតិកាលទី១ មានកំណត់ត្រឹម៥ឆ្នាំ។

-សមាជិកព្រឹទ្ធសភាចំនួន២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ

-សមាជិកព្រឹទ្ធសភាចំនួន២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។

-សមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភាគឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច៤០ឆ្នាំ មានសញ្ជាតិខ្មែរពីកំណើត។

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ។សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់ចំណាច់។ ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរ

---

[1] អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣*

ដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិចបីខែ។

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា។ សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។

## ២-មុខងារសំខាន់ៗរបស់ព្រឹទ្ធសភា

### ២.១-មុខងារនីតិកម្ម

ពិនិត្យឱ្យយោបល់លើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភានិងផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់។ តួនាទីសំខាន់របស់ព្រឹទ្ធសភាគឺការពិនិត្យឡើងវិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ។រដ្ឋសភាមិនអាចបញ្ជូនច្បាប់ដែលខ្លួនបានអនុម័តរួចហើយឱ្យព្រះមហាក្សត្រឡាយព្រះហស្ថ លេខាប្រកាសឱ្យប្រើប្រាស់ជាផ្លូវការមុនពេលដាក់ធ្វងឱ្យព្រឹទ្ធសភាពិនិត្យបានឡើយ។ រដ្ឋធម្មនុញ្ញមិនបានផ្តល់ឱ្យព្រឹទ្ធសភានូវអំណាចអនុម័តច្បាប់ ឬអំណាចជំទាស់អត្ថបទច្បាប់ឡើយ ប៉ុន្តែផ្តល់នូវតួនាទីប្រឹក្សា ឬអំណាចធ្វើអនុសាសន៍ដែលរដ្ឋសភាបានអនុម័ត។ ទោះបីជាព្រឹទ្ធសភាអាចធ្វើការបដិសេធ ឬស្នើធ្វើវិសោធនកម្មទៅលើអត្ថបទច្បាប់ ព្រឹទ្ធសភាពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភាទទួលយកអនុសាសន៍របស់ខ្លួនឡើយ។

ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើកបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។

### ២.២-មុខងារតាមដានត្រួតពិនិត្យ

ព្រឹទ្ធសភាអាចតាមដានត្រួតពិនិត្យការងារ និងការអនុវត្តគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល ជាពិសេសត្រួតពិនិត្យការប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាល។

**-ត្រួតពិនិត្យការអនុវត្តច្បាប់៖** ព្រឹទ្ធសភាមានតួនាទីសំខាន់ក្នុងការតាមដានដំណើរការងាររបស់ស្ថាប័នរដ្ឋ និងត្រួតពិនិត្យយ៉ាងទៀតទាត់អំពីការអនុវត្តច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ។

**-ត្រួតពិនិត្យការអនុវត្តកម្មវិធី និងផែនការរបស់រដ្ឋាភិបាល៖** ព្រឹទ្ធសភាក៏ដើរតួនាទីសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តកម្មវិធី និងផែនការរបស់រាជរដ្ឋាភិបាលលើការងារប្រជាធិបតេយ្យ នីតិរដ្ឋ ការងារកែទម្រង់រដ្ឋ ការងារកាត់បន្ថយភាពក្រីក្រ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។

### ២.៣-មុខងារជាតំណាង

**-តំណាងសមូហភាពដែនដី** (ក្រុមប្រឹក្សាឃុំ-សង្កាត់)

ព្រឹទ្ធសភាតំណាងភូមិភាគនិងសមូហភាពដែនដី (ក្រុមប្រឹក្សាឃុំ-សង្កាត់)។ មាត្រា៩ និងមាត្រា១១នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានបង្ហាញច្បាស់អំពីអត្តសញ្ញាណរបស់សមាជិកព្រឹទ្ធសភា ។

សមាជិកព្រឹទ្ធសភាត្រូវចុះសួរសុខទុក្ខ ជួយដោះស្រាយបញ្ហា សំណូមពររបស់ប្រជាពលរដ្ឋតាមមណ្ឌលរៀងខ្លួន ឬតាមរាជធានីខេត្តទាំងឡាយទូទាំងប្រទេសឱ្យអស់លទ្ធភាព និងត្រូវទាក់ទងជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

**-តំណាងស្ថាប័នជាតិ**

សមាជិក២រូបតែងតាំងដោយព្រះមហាក្សត្រ និង២រូបទៀតជ្រើសតាំងដោយរដ្ឋសភា។ ព្រឹទ្ធសភាក៏តំណាងព្រះមហាក្សត្រ និងរដ្ឋសភា ហើយក៏ជាអ្នកសម្របសម្រួលការងាររដ្ឋសភា និងរាជរដ្ឋាភិបាល ។

អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ[2] មាត្រា១១២ បញ្ជាក់ថាព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។

ក្រៅពីនេះ ព្រឹទ្ធសភាក៏មានមុខងារសំខាន់ៗផ្សេងទៀត ដូចជា សហប្រតិបត្តិការអន្តរជាតិ និងអភិវឌ្ឍស្ថាប័ន។

## ៣-គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការជំនាញ

គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភាត្រូវបានបង្កើតឡើង ដើម្បីធានាដំណើរការព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំ និងសម្រេចពីរបៀបវារៈប្រជុំពេញអង្គ និងកិច្ចការធំៗរបស់ព្រឹទ្ធសភា។

សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍មានដូចតទៅ៖

-ប្រធានព្រឹទ្ធសភា

-អនុប្រធានទាំងពីរ

-ប្រធានគណៈកម្មការនានានៃព្រឹទ្ធសភា ។

ព្រឹទ្ធសភាបង្កើតគណៈកម្មការជំនាញនានាចំនួន១០ ដើម្បីទទួលពិនិត្យសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នានានិងជាពិសេសទទួលបន្ទុកទៅតាមមុខជំនាញរបស់ខ្លួនក្នុងការត្រួតមើលកិច្ចការរបស់រាជរដ្ឋាភិបាល។

---
[2] ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

**គណៈកម្មការជំនាញទាំង១០ គឺ៖**

១-គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៦-គណៈកម្មការនីតិកម្ម និងយុត្តិធម៌

៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី

៩-គណៈកម្មការសាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគររូបនីយកម្ម និងសំណង់

១០-គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ។

**៤-មណ្ឌលបោះឆ្នោតព្រឹទ្ធសភា**

មណ្ឌលបោះឆ្នោតព្រឹទ្ធសភាត្រូវរៀបចំ និងបែងចែកជា៨ (ប្រាំបី) ភូមិភាគ។ អាសនៈនៅក្នុងព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវកំណត់ត្រឹមចំនួន៥៨ (ហាសិបប្រាំបី) ដោយបែងចែកតាមភូមិភាគដូចខាងក្រោម៖

-ភូមិភាគទី១ រាជធានីភ្នំពេញ មាន៦ (ប្រាំមួយ) អាសនៈ

-ភូមិភាគទី២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មាន៨ (ប្រាំបី) អាសនៈ

-ភូមិភាគទី៣ ខេត្តកណ្ដាល មាន៥ (ប្រាំ) អាសនៈ

-ភូមិភាគទី៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន មាន១០ (ដប់) អាសនៈ

-ភូមិភាគទី៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប មាន ៧ (ប្រាំពីរ) អាសនៈ

-ភូមិភាគទី៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន ៧ (ប្រាំពីរ) អាសនៈ

[3] ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

-ភូមិភាគទី៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ មាន៩ (ប្រាំបួន) អាសនៈ

-ភូមិភាគទី៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី មាន៦(ប្រាំមួយ)អាសនៈ។

**•ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ ១៩៩៩ ដល់បច្ចុប្បន្ន**

**-នីតិកាលទី ១ ៖ (១៩៩៩-២០០៦)**

ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយការតែងតាំងទាំងអស់។ ព្រឹទ្ធសភានីតិកាលទី១ មានសមាជិកចំនួន៦១ រូប ក្នុងនោះគណបក្សប្រជាជនកម្ពុជាមានចំនួន៣១ រូប គណបក្សហ៊្វុនស៊ិនប៉ិច២១ រូប គណបក្សសម រង្ស៊ី៧ រូប និង២ រូបទៀតចាត់តាំងដោយព្រះមហាក្សត្រ សម្រាប់រយៈពេល ៥ ឆ្នាំ។ ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាលរបស់ខ្លួនចំនួន ២ ដង (ម្តង ១ឆ្នាំ) ។

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី១ មាន សម្តេច **ជា ស៊ីម** ជាប្រធាន (គណបក្សប្រជាជនកម្ពុជា) ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័នមុនីរ៉ាក់** ជាអនុប្រធានទី១ (គណបក្សហ៊្វុនស៊ិនប៉ិច) និងឯកឧត្តម **ញឹក ប៊ុនឆៃ** ជាអនុប្រធានទី២ (គណបក្សហ៊្វុនស៊ិនប៉ិច) ។

លុះមកដល់ខែសីហា ឆ្នាំ២០០៤ ឯកឧត្តម **ញឹក ប៊ុនឆៃ** បានលាលែងទៅបំពេញការងារក្នុងរាជរដ្ឋាភិបាល ហើយគណបក្សហ៊្វុនស៊ិនប៉ិចបានស្នើតែងតាំងឯកឧត្តម **ប៉ោ ប៊ុនស្រ៊ី** ជំនួស។

**-នីតិកាលទី ២ ៖ (២០០៦-២០១២)**

ព្រឹទ្ធសភានីតិកាលទី២ កើតចេញពីការបោះឆ្នោតអសកលនាថ្ងៃអាទិត្យទី២២ ខែមករា ឆ្នាំ២០០៦ សម្រាប់រយៈពេល៦ ឆ្នាំ។ នៅក្នុងនីតិកាលទី២ នេះ សមាជិកព្រឹទ្ធសភាមានចំនួន៦១ រូប ដូចនីតិកាលទី១ ដែរ ក្នុងនោះ ៤៥ រូបមកពីគណបក្សប្រជាជនកម្ពុជា១០ រូបមកពីគណបក្សហ៊្វុនស៊ិនប៉ិច២ រូបមកពីគណបក្សសម រង្ស៊ី២ រូបចាត់តាំងដោយព្រះមហាក្សត្រ និង ២រូបទៀតជ្រើសតាំងដោយរដ្ឋសភា។

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានៅក្នុងនីតិកាលទី២ មាន សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ជាប្រធាន (គណបក្សប្រជាជនកម្ពុជា) សម្តេច**ស៊ីសុវត្ថិ ជីវ័នមុនីរ៉ាក់** ជាអនុប្រធានទី១ (គណបក្សហ៊្វុនស៊ិនប៉ិច) និងឯកឧត្តម **តេព ងន** ជាអនុប្រធានទី២ (គណបក្សប្រជាជនកម្ពុជា)។

**-នីតិកាលទី ៣ ៖ (២០១២-២០១៨)**

ការបោះឆ្នោតអសកលជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៣ បានប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។

សម្រាប់នីតិកាលទី៣ នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន៦១ រូប ដូចនីតិកាលទី១ និងនីតិកាលទី២ ដែរ ក្នុងនោះមកពីគណបក្សប្រជាជនកម្ពុជា៤៦ រូប គណបក្សសម រង្ស៊ី ១១ រូប ២ រូបចាត់តាំងដោយព្រះមហាក្សត្រ និងជ្រើសតាំងដោយរដ្ឋសភា២ រូប។

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី៣ មានសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ជាប្រធាន(គណបក្សប្រជាជនកម្ពុជា) ឯកឧត្តម **សាយ ឈុំ** ជាអនុប្រធានទី១ (គណបក្សប្រជាជនកម្ពុជា) និងឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២(គណបក្សប្រជាជនកម្ពុជា) ។

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** បានទទួលមរណភាព។ ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នាថ្ងៃទី៩ខែមិថុនា ឆ្នាំ២០១៥សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានព្រឹទ្ធសភា ឯកឧត្តម **នៃ ប៉េណា** ជាអនុប្រធានទី១។

**-នីតិកាលទី៤ ៖ (២០១៨-២០២៤)**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ បានប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។ សម្រាប់នីតិកាលទី៤ នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន៦២ រូប ក្នុងនោះមកពីគណបក្សប្រជាជនកម្ពុជាចំនួន៥៨ រូប តែងតាំងដោយព្រះមហាក្សត្រ២ រូប និងជ្រើសតាំងដោយរដ្ឋសភា២ រូប។

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា នីតិកាលទី៤ មានសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ជាប្រធាន ឯកឧត្តម **នៃ ប៉េណា** ជា អនុប្រធានទី១ និងឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២។

ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ ឯកឧត្តម **នៃ ប៉េណា** ទទួលមរណភាព។ ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តម **ស៊ឹម កា** ត្រូវបានព្រឹទ្ធសភាបោះឆ្នោតជ្រើសរើសជាអនុប្រធានទី១។

**-នីតិកាលទី ៥ ៖ (២០២៤-២០៣០)**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ បានប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤។ សម្រាប់នីតិកាលទី៥ នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន៦២ រូប ដូចនីតិកាលទី៤ ដែរ ក្នុងនោះមកពីគណបក្សប្រជាជនកម្ពុជា ចំនួន៥៥ រូប គណបក្សឆន្ទៈខ្មែរ ចំនួន៣ រូប តែងតាំងដោយព្រះមហាក្សត្រ២ រូប និងជ្រើសតាំងដោយរដ្ឋសភា២ រូប។

សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា នីតិកាលទី៥ មាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធាន ឯកឧត្តម

**ប្រាក់ សុខុន** ជាអនុប្រធានទី១ និងឯកឧត្តម **អ៊ុច បូររិទ្ធ** ជាអនុប្រធានទី២។

ព្រឹទ្ធសភាគឺជាអង្គការនីតិប្បញ្ញត្តិរបស់ជាតិ ដែលដើរតួនាទីដ៏សំខាន់ក្នុងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មសង្គមនិងក្នុងការអភិវឌ្ឍជាតិជានីតិរដ្ឋ។ ការរួមវិភាគទានក្នុងដំណើរស្ថិរភាពភាវូបនីយកម្មរបស់នយោបាយជាតិដែលជាស្នូលនៃការពង្រឹងរាល់នយោបាយក្នុងការសម្របសម្រួលផ្សះផ្សារបញ្ហារបស់ជាតិនិងបង្កើតភាពរុងរឿង រីកចម្រើន ភាពសម្បូរសប្បាយដល់ប្រទេសនិងប្រជាជន។ ព្រឹទ្ធសភា កំពុងផ្សារភ្ជាប់ខ្លួនទៅនឹងវិមជ្ឈការ វិសហមជ្ឈការ ជាបច្ចុប្បន្នភាពនៃកំណែទម្រង់រដ្ឋបាលសាធារណរបស់ជាតិ។

តាំងពីឆ្នាំ១៩៩៩ រហូតមកដល់ពេលនេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ព្រឹទ្ធសភាបានរួមចំណែកយ៉ាងសកម្ម ជួយដោះស្រាយបញ្ហាជាច្រើនសម្រាប់បម្រើដល់ការគ្រប់គ្រងរដ្ឋ សេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងតម្រូវការនៃការធ្វើសមាហរណកម្ម កម្ពុជានៅក្នុងក្របខ័ណ្ឌតំបន់ និងលើឆាកអន្តរជាតិ។

នៅក្នុងសុន្ទរកថា ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤ ក្នុងឱកាសដែលសម្តេចត្រូវបានជ្រើសរើសជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានប្រសាសន៍ថា« **ចាប់តាំងពីពេលចាប់បដិសន្ធិមក ព្រឹទ្ធសភាបានបង្ហាញឱ្យឃើញនូវសមត្ថភាពវិសេសវិសាល ភាពចាស់ទុំខាងនយោបាយ និងការទទួលខុសត្រូវខ្ពស់បំផុតក្នុងការបម្រើប្រយោជន៍ស្នូលរបស់ប្រទេសជាតិនិងប្រជាជនយើង សម្រេចបាននូវសមិទ្ធផលនិងវឌ្ឍនភាពគួរឱ្យស្ញប់ស្ញែងជាច្រើន ក្នុងពេលអនុវត្តមុខងារស្នូលទាំងបីរបស់ខ្លួន ពោលគឺ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់និងគោលនយោបាយ និងមុខងារតំណាង**»។

•ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា (១៩៩៩-បច្ចុប្បន្ន)



១-សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** (១៩៩៩-២០១៥)

២-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** (២០១៥-២០២៤)

៣-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (២០២៤-បច្ចុប្បន្ន)

**គន្ថនិទ្ទេស**


១-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

២-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

៣-ទំព័រហ្វេសប៊ុក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៤-ហែម ឡាច៖ ស្ថាប័ននយោបាលកម្ពុជាបច្ចុប្បន្ន ឆ្នាំ២០២៣

៥-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

៦-https://senate.gov.kh/about-senate/senate-history/

៧-https://senate.gov.kh/senate-page/senate-roles/